**សកម្មភាព** ៖ សត្វត្រឡោកដូង

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

ការរស់នៅប្រចាំថ្ងៃ (ការការស្វែងយល់ដោយសង្កេត)

**វិទ្យាសាស្ត្រ**

ការរស់នៅប្រចាំថ្ងៃ (ការស្វែងយល់ដោយការសង្កេត)

**សិក្សាសង្គម**

គំនូរ និងសកម្មភាពកសាង (ការយល់ដឹង ការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព)

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីររបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬ លេងល្បែង។

**(វិទ្យាសាស្ត្រ)** ប្រាប់បានពីឈ្មោះសត្វចិញ្ចឹម សត្វព្រៃ សត្វស្លាបឬលើសពីនេះ។

**(សិក្សាសង្គម)** ប្រាប់បានពីរបៀបធ្វើសកម្មភាពបង្កើតបានជារូបភាពផ្សេងៗ។

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "តើអ្នកពូកែអី? "

**កម្រិត** ៖ មធ្យម ទាប ខ្ពស់

**រយៈពេល** ៖ ៣០នាទី

**ឧបករណ៍** ៖ ត្រឡោកដូងលើសពីពីរចំហៀង មួយចំហៀងសម្រាប់កុមារម្នាក់ៗ និងមួយចំហៀងទៀតសម្រាប់អ្នក។ ម្សៅពណ៌ កាវ ប្រអប់ ឬចាន និងសម្ភារសម្រាប់ផាត់ពណ៌។

**ការរៀបចំ** ៖ ការរៀបចំសម្ភារមួយចំនួនដូចជា

-បោះពុម្ពរូបភាព ឬគូរលើត្រឡោកដូងដោយខ្លួនអ្នក ដើម្បីផ្ដល់គំនិត និងវិធីសាស្ត្រខ្លះៗដល់ក្មេងៗ។

-ធ្វើម្សៅពណ៌(បី ឬបួនពណ៌សម្រាប់ក្រុមនីមួយៗ) និងកាវ។

-បែងចែកម្សៅពណ៌ដាក់ក្នុងប្រអប់តូចៗដោយមានប្រដាប់ប្រដាសម្រាប់គូរ និងផាត់ពណ៌ឱ្យបានគ្រប់គ្រាន់សម្រាប់ក្មេងម្នាក់ៗ។

**សេចក្តីណែនាំ៖**

1. ថ្ងៃនេះអ្នកគ្រូនឹងនាំកូនៗច្នៃធ្វើ**សត្វត្រឡោកដូង**ជាមួយកូនៗទាំងអស់គ្នា។
2. សួរក្មេងៗ៖ តើសត្វស្លាបមានអ្វីខ្លះ? បាទ/ចាស សត្វ ឃ្មុំ ចាប
   តើសត្វចិញ្ចឹមមានអ្វីខ្លះ? បាទ/ចាស សត្វ ឆ្មា ឆ្កែ
   តើសត្វព្រៃមានអ្វីខ្លះ? បាទ/ចាស ខ្លា គោ ដំរី
3. បង្ហាញរូបភាពគំរូសត្វត្រឡោកដូងដែលបានធ្វើរួចទៅកាន់ក្មេងៗទាំងអស់។
4. ចែកត្រឡោកដូងមួយចំហៀងដល់ក្មេងម្នាក់មួយ។
5. សួរក្មេងៗ៖ តើកូនៗចង់ច្នៃធ្វើសត្វត្រលោកដូងរូបអ្វីដែរ? សត្វឃ្មុំ អណ្តើក សត្វកំពឹងដូង…។
6. ឱ្យក្មេងៗផាត់ពណ៌លើត្រឡោកដូងដោយបែងចែកជាក្រុម តាមពណ៌ដែលពួកគេត្រូវការផាត់។
7. បន្ទាប់មកចាប់ផ្តើមគូរភ្នែក ច្រមុះ ត្រចៀក ជើង អវយវៈដ៏ទៃទៀត។
8. យើងអាចកាត់ក្រដាសជារង្វង់បិទធ្វើជាភ្នែក ឬច្រមុះ ត្រចៀក ជើង អវយវៈដ៏ទៃទៀតក៏បានដែរ។
9. រួចផាត់ពណ៌ច្នៃឱ្យចេញជាប្រភេទសត្វដែលកូនៗចង់បាន។
10. នៅពេលរង់ចាំថ្នាំពណ៌ស្ងួតល្អ អ្នកគ្រូអាចនិយាយអំពីសត្វផ្សេងៗដែលកុមារតាមក្រុមបានគូរ និងផាត់ពណ៌។ ឧទាហរណ៍៖ កូនៗនៅក្នុងក្រុមទី ១បានបង្កើតគឺជាសត្វ ឃ្មុំពណ៌លឿង ។
11. សរសេរឈ្មោះសត្វត្រលោកដូងដែលក្មេងៗធ្វើរួចនៅលើក្តារខៀន។

**បម្រែបម្រួល៖**

ពួកគេអាចគូររូបសត្វផ្សេងៗគ្នា ឬរូបផ្សេងក្រៅពីរូបសត្វក៏បានដែរ។ សម្រាប់ក្រុមនីមួយៗយើងត្រូវបែងចែកប្រភេទសត្វផ្សេងៗគ្នា (ឧទាហរណ៍៖ សត្វត្រី សត្វចាប សត្វគោ…) ។

